training.com.au

# គ្រប់គ្រងរស់អំពី training.com.au

Training.com.au ផ្តល់នូវចំណុចលទ្ធភាពតែមួយដើម្បីទទួលយកពត៌មាន ផលិតផល និងកិច្ចបំរើផ្នែកអប់រំ និងហ្វឹកហ្វឺនខាងវិជ្ជាជីវៈនៅក្នុងប្រទេសអូស្ត្រាលី។

ផ្លូវចូលធំនេះត្រូវបានបង្កើតឡើងរួមគ្នាជាមួយនឹងអាជ្ញាធរហ្វឹកហ្វឺនរដ្ឋ និងដែនដី និងអាជ្ញាធរហ្វឹកហ្វឺនជាតិនៃប្រទេសអូស្ត្រាលី។ នេះគឺជាច្រកចេញចូលដែលនាំទៅរកគេហទំព័រ និងកិច្ចបំរើផ្សេងៗទៀតជាច្រើន។

## ការជួយដល់អាជីវកម្ម

ការហ្វឹកហ្វឺនអាចមានឥទ្ធិពលដល់អាជីវកម្មរបស់លោកអ្នក។ វាអាចជួយកែលំអការបំពេញកិច្ចការរបស់បុគ្គលិក ហើយមានឥទ្ធិពលយ៉ាងល្អដល់ផលចំណេញរបស់លោកអ្នក។

Training.com.au ជួយឲ្យបានកាន់តែងាយស្រួលឡើងសំរាប់និយោជក ដើម្បីរកឃើញនូវអ្វីៗដែលគេចង់ដឹងអំពីការធ្វើវិនិយោគក្នុងផ្នែកអប់រំ និងហ្វឹកហ្វឺនខាងវិជ្ជាជីវៈ។

ផ្នែកអាជីវកម្ម និងនិយោជកនៃផ្លូវចូលធំនេះរាប់បញ្ចូលទាំងពត៌មានដូចជា:

- ផលប្រយោជន៍នៃការហ្វឹកហ្វឺន និងការបង្កើនជំនាញការបុគ្គលិក
- ការប៉ាន់ស្មង់លើសេចក្តីត្រូវការផ្នែកហ្វឹកហ្វឺនរបស់អាជីវកម្មលោកអ្នក និងបុគ្គលិករបស់លោកអ្នក
- ថវិកាដែលអាចទទួលយកបានពីរដ្ឋាភិបាលអូស្ត្រាលី រដ្ឋ និងដែនដី
- របៀបជ្រើសរើសយកការហ្វឹកហ្វឺនដែលត្រឹមត្រូវ
- របៀបចែកចាយការហ្វឹកហ្វឺនទៅដល់និយោជិត
- ការចំណាយទៅលើការហ្វឹកហ្វឺន និងកាតព្វកិច្ចទាំងឡាយ។

វារាប់បញ្ចូលទាំងពត៌មានអំពីកម្មវិធីហ្វឹនហ្វឺនដែលមានផ្តល់ របៀបចែកចាយការហ្វឹកហ្វឺន និងករណីសិក្សា។

លោកអ្នកនឹងបានទទួលធនធានទាំងឡាយផងដែរ ដែលអាចយកប្រើដើម្បីជួយអ្នកគ្រប់គ្រងបង្កើត និងរៀបចំចាត់ចែងករណីអាជីវកម្មដ៏រឹងមាំសំរាប់ការហ្វឹកហ្វឺន។

## ឲ្យមានការចូលរួមពីកូនជាងថ្មី

កូនជាងថ្មីគឺជាន័យដែលគ្របដណ្តប់គ្រប់ទាំងការធ្វើជាកូនជាង និងការហាត់ហ្វឹកហ្វឺន។

កម្មវិធីហ្វឹកហ្វឺនធ្វើកូនជាងថ្មីត្រូវបានគ្រោងឡើងដោយឧស្សាហកម្ម សំរាប់ឧស្សាកម្ម ហើយមានផ្តល់ច្រើនជាង ៥០០មុខរបរពេញទូទាំងប្រទេសអូស្ត្រាលីចាប់ពីការសាងសង់ ទៅពហុផ្សព្វផ្សាយពត៌មានតាមរយៈខុមព្យូធើរ។

ផ្នែកធ្វើជាកូនជាង និងការហាត់ហ្វឹកហ្វឺនរបស់ Training.com.au ផ្តល់នូវការណែនាំទៅដល់និយោជកដែលបានជួល ឬចាប់អារម្មណ៍ក្នុងការជួលកូនជាងថ្មី។

ពត៌មាននៅក្នុងផ្នែកនេះរាប់បញ្ចូលទាំង:

- ផលប្រយោជន៍នៃការជួលកូនជាងថ្មី
- របៀបជួលកូនជាងថ្មី
- ថវិកាផ្គត់ផ្គង់សំរាប់និយោជកដែលជួលកូនជាងថ្មី ដែលអាចទទួលយកបានពីរដ្ឋាភិបាលអូស្ត្រាលី រដ្ឋ និងដែនដី
- ការចំណាយ និងកាតព្វកិច្ចទាំងឡាយរបស់និយោជក។

## ភាពដែលអាចបត់បែនបាន

កម្មវិធីកូនជាងថ្មី គឺអាចបត់បែនបាន ហើយផ្តល់នូវជម្រើសហ្វឹកហ្វឺនដ៏ធំទូលាយ។ កម្មវិធីនេះផ្តល់នូវឱកាសបំពេញការងារពេញពេញ ឬពាក់កណ្តាលពេល។ នេះមានន័យថាលោកអ្នកអាចបំពេញចន្លោះវេនបុគ្គលិកសំរាប់រយៈពេលណាមួយគឺចាប់ពីមួយថ្ងៃ ទៅពីរ ឬបីថ្ងៃក្នុងមួយអាទិត្យ។

## ការជួយដល់អង្គការហ្វឹកហ្វឺន

អង្គការហ្វឹកហ្វឺនដែលចុះឈ្មោះស្របច្បាប់ (RTO) គឺជាអ្នកផ្តល់កិច្ចបំរើហ្វឹកហ្វឺនដែលមានគុណភាពដែលត្រូវបានរដ្ឋទទួលស្គាល់ ហើយបំពេញទៅលើខ្នាតគំរូជាតិ។

ផ្នែកនៃអង្គការហ្វឹកហ្វឺនរបស់ training.com.au ផ្តល់នូវពត៌មានសំរាប់ RTO ដែលមានរួចហើយ និងដែលបំរុងនឹងធ្វើជា RTO ដូចជា:

- ផលប្រយោជន៍នៃការធ្វើជា RTO
- របៀបធ្វើជា RTO
- កាតព្វកិច្ច និងខ្នាតគំរូទាំងឡាយដែល RTO ត្រូវបំពេញ
- ថវិកាផ្គត់ផ្គង់ដែលអាចទទួលយកបានពីរដ្ឋាភិបាលអូស្ត្រាលី រដ្ឋ និងដែនដី
- អ្វីដែលទាក់ទិនក្នុងការចាប់ដំណើរការ RTO
- របៀបបំពេញទៅលើសេចក្តីត្រូវការរបស់សិស្សដែលកំពុងហ្វឹកហ្វឺន។

## ការចែកចាយដ៏ល្អប្រសើរ

RTO ត្រូវបានទទួលស្គាល់ចំពោះការចែកចាយដ៏ល្អប្រសើរក្នុងផ្នែកហ្វឹកហ្វឺន ហើយមានសិទ្ធិប្រើនិមិត្តសញ្ញាហ្វឹកហ្វឺនសំរាប់គ្រប់ទាំងសញ្ញាប័ត្រ ដែលត្រូវបានទទួលស្គាល់ពេញទូទាំងប្រទេស។ និមិត្តសញ្ញានេះផ្តល់ជាឧបករណ៍ពាណិជ្ជកម្មដ៏មានតម្លៃដែលគ្រាន់តែក្រឡេកឃើញភ្លាមនោះ បង្ហាញឲ្យឃើញថាការហ្វឹកហ្វឺនដែលលោកអ្នកផ្តល់ គឺមានគុណភាពដែលត្រូវបានធានា ហើយត្រូវបានទទួលស្គាល់ជាផ្លូវការពេញទូទាំងប្រទេស។

សិស្ស និងអាជីវកម្មដែលជួលកូនជាងនឹងមានការទុកចិត្តថាជំនាញការដែលគេបានទទួល គឺមានគុណភាពដ៏ខ្ពស់ ហើយមានតម្លៃពេញទូទាំងប្រទេស។